Insert size 140x250 mm

បរិយាយប័ណ្ណឱសថ
សេទីម៉ែត

SETIMED

I. រូបភាពឱសថ:

ជាឱសថប្រភេទគ្រាប់សម្រាប់លេបក្នុង១ប្រអប់មាន២បន្ទះ ក្នុង១បន្ទះមាន១០គ្រាប់។

II. សមាសធាតុ:ក្នុង១គ្រាប់មាន

Levocetirizine Dihydrochoride.....5mg

III. គុណភាពព្យាបាល:

-បន្ទុរោគសញ្ញាអាល្លែកហ្ស៊ីច្រមុះ និងភ្នែកតាមរដូវកាល
-បន្ទុរោគសញ្ញាកន្ទាលត្រអាកពុំរ៉ៃ
-ហើមសរសៃឈាម
-រមាស់
-ព្រូតិកម្មអាល្លែកហ្ស៊ីដោយសារចំណីអាហារ ឱសថ និងសារធាតុធ្វើឱ្យរមាស់ដទៃទៀត អាល្លែកហ្ស៊ីទៅនឹងសត្វចិច។ ការព្យាបាលទុំលំទុំលាយ
(ជំងឺរលាកស្បែក ត្រអក រលាកស្បែកដោយប៉ះសារធាតុផ្សេងៗ)

IV. ការហាមប្រើ:

-អ្នកមានប្រវត្តិងាយមានប្រតិកម្មទៅនឹង Levocetirizine។
-អ្នកជំងឺខ្សោយតម្រងនោមយ៉ាងហោច creatinine clearance ទាបជាង ១០មល/នាទី
-ស្ត្រីមានផ្ទៃពោះ និងបំបៅដោះកូន
-ក្មេងអាយុក្រោម៦ឆ្នាំ

V. ការប្រុងប្រយ័ត្នប្រើ:

អ្នកជំងឺខ្សោយតម្រងនោមពុំរ៉ៃ (ទាមទារការកែតម្រូវកម្រិតប្រើ) អាយុច្រើន (អាចថយចុះកម្រិតគ្រោះរបស់តម្រងនោម)។
ដោយ Setimed បញ្ចេញក្នុងទម្រង់មិនឆ្លាស់ប្តូរតាមតម្រងនោម វាមិនអាចកើតឡើងដែលថាការបញ្ចេញនៃ Setimed ថយចុះចំពោះអ្នកជំងឺខ្សោយថ្លើម។
ការប្រើប្រាស់ Levocetirizine Dihydrochoride មិនត្រូវបានណែនាំចំពោះក្មេងអាយុក្រោម៦ឆ្នាំ។នៅកម្រិតប្រើ មិនមានអន្តរកម្មជាមួយជាតិអាល់កុល។ ទោះបីយ៉ាងណា
ការប្រុងប្រយ័ត្នត្រូវបានណែនាំប្រសិនបើពិសារស្រាស្របពេលគ្នា។
ត្រូវប្រុងប្រយ័ត្នចំពោះអ្នកជំងឺឆ្លុតក្រូក និងអ្នកជំងឺស្ថិតក្នុងសភាពគ្រោះថ្នាក់ដោយការប្រកាច់។
ជៀសវាងធ្វើការងារដែលទាមទាការផ្តោតស្មារតីពេញលេញដូចជា បើកបរ ឬប្រើប្រាស់ម៉ាស៊ីននៅពេលប្រើ Setimed។

ផលរំខាន:

-វិបត្តិសរសៃប្រសាទ: ឈឺក្បាល ដេកលើវ។ អស់កំលាំង និងចុះខ្សោយ
-ប្រព័ន្ធសរសៃឈាមបេះដូង: បេះដូងដើរញាប់
-វិបត្តិភ្នែក: ស្រវាំងភ្នែក
-វិបត្តិថ្លើមទឹកប្រមាត់: រលាកថ្លើម
-ប្រព័ន្ធភាពស៊ាំ: ពិបាកដកដង្ហើម
-ប្រព័ន្ធរំលាយអាហារ: ស្ងួតមាត់ ចង្អោរ
-វិបត្តិស្បែក និងជាលិកាទន់: រមាស់ កន្ទួលស្បែក កន្ទាលត្រអាក
-ផ្សេងៗ: ឡើងទម្ងន់ ឈឺពោះ ឈឺសាច់ដុំ អង់ស៊ីមថ្លើមប្រែប្រួល

អន្តរកម្មឱសថ:

មានការថយចុះបន្តិចបន្តួច (១៦%) ក្នុងការបញ្ចេញ Cetirizine បង្កដោយ Theophilline ក្នុងកម្រិតប្រើ៤០០មក្រ។ត្រូវបង្កើនកម្រិតប្រើ Theophilline
ខ្ពស់ ទើបមានប្រសិទ្ធភាពខ្ពស់។ការពន្រ្តីកវិសាលភាពនៃការស្រូបចូលរបស់ Levocetirizine មិនត្រូវបានកាត់បន្ថយដោយសារអាហារ ថ្វីបើអត្រាស្រូបចូលថយចុះ។
Ritonavir បង្កើនAUC របស់ Cetirizine ក្នុងឈាមប្រហែល ៤២% ស្របជាមួយការកើនឡើងនៃការបញ្ចេញចោលពាក់កណ្តាល (៥៣%) និងថយចុះការបញ្ចេញចោល
Cetirizine (២៩%)។ Ritonavir មិនត្រូវបានកត់សំគាល់ើញមានការកែប្រែដោយការប្រើស្របគ្នាជាមួយ Cetirizine។ ចំពោះអ្នកជំងឺដែលងាយមានប្រតិកម្ម ការប្រើ
ស្របគ្នានៃ Cetirizine ឬ Levocetirizine និងជាតិអាល់កុល ឬឱសថរំងាប់អារម្មណ៍ដទៃទៀត អាចមានប្រសិទ្ធភាពលើប្រព័ន្ធសរសៃប្រសាទ ថ្វីបើវាបង្ហាញថាការផ្សំល្បាយ
ស្មើគ្នានៃcetirizine មិនមានឥទ្ធិពលដោយជាតិអាកុល។

VI. កម្រិតនិងរបៀបប្រើ:

ឱសថនេះត្រូវប្រើតាមមាត់ លេបទាំងមូលជាមួយទឹក ហើយអាចលេបពេលអាហារ ឬក្រៅពេល អាហារ។

មនុស្សពេញវ័យ និងក្មេងចាប់ពី៦ឆ្នាំឡើង: កម្រិតប្រើបានណែនាំគឺ៥មក្រ លេប១ដងក្នុង១ថ្ងៃ។
Setimed ហាមប្រើចំពោះកុមារក្រោម៦ឆ្នាំ ដោយសារទិន្នន័យមិនគ្រប់គ្រាន់លើសុវត្ថិភាព និង ប្រសិទ្ធភាព។

មនុស្សចាស់ជរា: មិនមានទិន្នន័យណែនាំឱ្យបន្តយកកម្រិតប្រើចំពោះមនុស្សចាស់ជរា ដែលមានមុខងារតម្រងនោមធម្មតា។

ការកែតម្រូវកម្រិតប្រើចំពោះអ្នកខ្សោយតម្រងនោម និងថ្លើម:

ការខ្សោយតម្រងនោមធ្ងន់ធ្ងរ (CLCR = 10-30ml/min): កម្រិតប្រើ២.៥មក្រលេប១ដងក្នុង១អាទិត្យ(លេបម្តងក្នុងរយៈពេល៣ទៅ៤ថ្ងៃ) ត្រូវបានណែនាំ។
ការខ្សោយតម្រងនោមមធ្យម (CLCR = 30-50ml/min): កម្រិតប្រើ២.៥មក្រលេប១ដងក្នុង១ថ្ងៃត្រូវបានណែនាំ។

ការរក្សាទុក: ត្រូវរក្សាទុកនៅសីតុណ្ហភាពក្រោម៣០អង្សាសេនៅកន្លែងស្ងួតនិងមិនឱ្យត្រូវពន្លឺថ្ងៃ។

VII. លេខយោងពិភាក: CAM N0868IP-17

VIII. ផលិតដោយ: Brawn Laboratories Ltd.
13, NIT, Industrial Area, Faridabad, Haryana (INDIA)
បានបកប្រែដោយនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង